# ការសច្ចាអំពីសុវត្ថិភាពនៃការប្រើអ៊ិនធ័រណិត - ពីកូនរបស់លោកអ្នក

១. ខ្ញុំនឹងមិនឲ្យព័ត៌មានផ្ទាល់ខ្លួនទៅអ្នកណាម្នាក់ ដោយគ្មានការអនុញ្ញាតពីមាតាបិតារបស់ខ្ញុំ ដូចជា អាស័យដ្ឋាន លេខទូរស័ព្ទ របស់ខ្ញុំ អាស័យដ្ឋាន/លេខទូរស័ព្ទ នៅកន្លែងធ្វើការ របស់មាតាបិតា។

២. ខ្ញុំនឹងជម្រាបមាតាបិតារបស់ខ្ញុំភ្លាម បើសិនជាខ្ញុំជួបប្រទះនូវអ្វីៗដែលធ្វើឲ្យខ្ញុំមិនស្រណុកចិត្ត។

៣. ខ្ញុំនឹងមិនយល់ព្រមទៅជួបជាមួយអ្នកណាម្នាក់ដែលខ្ញុំបាន«ជួប»តាមអ៊ិនធ័រណិត ដោយមិនបានសុំមាតាបិតារបស់ខ្ញុំជាមុនសិននោះទេ។ បើសិនជាមាតាបិតារបស់ខ្ញុំយល់ព្រមឲ្យជួប ខ្ញុំនឹងជួបនៅកន្លែងសាធារណៈ ហើយនាំ មាតា ឬ បិតា របស់ខ្ញុំទៅជាមួយ។

៤. ខ្ញុំនឹងពិភាក្សាជាមួយមាតាបិតារបស់ខ្ញុំអំពីការបង្ហោះ រូបថតខ្ញុំ និង រូបថត របស់អ្នកដទៃទៀត តាមអ៊ិនធ័រណិត ហើយមិនបង្ហោះរូបណាដែលមាតាបិតាខ្ញុំគិតថាមិនសមរម្យនោះទេ។

៥. ខ្ញុំនឹងមិនឆ្លើយតបទៅនឹងសារណាដែលថោកទាប ឬធ្វើឲ្យខ្ញុំមិនស្រណុកចិត្ត។ វាមិនមែនជាកំហុសរបស់ខ្ញុំទេ បើសិនជាខ្ញុំទទួលសារបែបនេះ។ បើសិនជាខ្ញុំទទួលសារបែបនេះ ខ្ញុំនឹងជម្រាបមាតាបិតារបស់ខ្ញុំភ្លាម។

៦. ខ្ញុំនឹងនិយាយជាមួយមាតាបិតារបស់ខ្ញុំ ដើម្បីឲ្យយើងរៀបចំវិន័យសម្រាប់ការប្រើអ៊ិនធ័រណិត និងការប្រើទូរស័ព្ទដៃ។ យើងនឹងសម្រេចថាតើខ្ញុំអាចប្រើអ៊ិនធ័រណិតនៅពេលណា រយៈពេលប៉ុន្មានដែលខ្ញុំអាចប្រើអ៊ិនធ័រណិត និងអ្វីៗដែលសមរម្យដែលខ្ញុំអាចមើលតាមអ៊ិនធ័រណិតបាន។ ខ្ញុំនឹងមិនចូលមើលអ្វីក្រៅពីនោះ ឬ ធ្វើខុសវិន័យ ដោយគ្មានការអនុញ្ញាតពីពួកគាត់ នោះទេ។

៧. ខ្ញុំនឹងមិនឲ្យពាក្យសម្ងាត់របស់ខ្ញុំទៅអ្នកណាម្នាក់ (ទោះជាមិត្តជិតស្និតរបស់ខ្ញុំក៏ដោយ) ក្រៅពីមាតាបិតារបស់ខ្ញុំ។

៨. ខ្ញុំនឹងសាកសួរមាតាបិតារបស់ខ្ញុំ មុននឹងចម្លងយក ឬ តម្លើង កម្មវិធីក្នុងកុំព្យូទ័រ ឬ ធ្វើអ្វីមួយដែលអាចនាំឲ្យមានបញ្ហាដល់កុំព្យូទ័រ ឬទូរស័ព្ទដៃ របស់យើង ឬ អាចនាំឲ្យប៉ះពាល់ដល់បញ្ហាផ្ទាល់ខ្លួនរបស់ក្រុមគ្រួសារ។

៩. ខ្ញុំនឹងធ្វើខ្លួនជាពលរដ្ឋល្អនៅពេលប្រើអ៊ិនធ័រណិត ហើយមិនធ្វើអ្វីដែលនាំឲ្យអ្នកដទៃឈឺចាប់ ឬ ធ្វើអ្វីខុសច្បាប់។

១០. ខ្ញុំនឹងជួយមាតាបិតារបស់ខ្ញុំឲ្យយល់ពីការសប្បាយរីករាយ និង ការរៀនសូត្រ តាមការប្រើអ៊ិនធ័រណិត ហើយបង្រៀនគាត់អំពី អ៊ិនធ័រណិត កុំព្យូទ័រ និងបច្ចេកវិទ្យាផ្សេងៗទៀត។